ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៥៥ អនក្រ.បក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
[illegible] រដ្ឋបាល
លេខ ៣២១៧
ថ្ងៃទី ០២..១០..១២
បញ្ជូន

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២៩៦/៣៤ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាទីជម្រកសត្វស្លាបទឹក ចុះនៅទីក្រុងរ៉ាំសា ប្រទេសអ៊ីរ៉ង់ នាថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៧១
- បានឃើញព្រះរាជក្រមលេខនស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មការអភិរក្សនិងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១២៣ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១២

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ ដែលជារតនសម្បត្តិធម្មជាតិមានជីវិតដ៏ពិសិដ្ឋ ជាពិសេសសម្រាប់បម្រើវិស័យអេកូទេសចរណ៍ និងអភិរក្សសត្វផ្សោតប្រកបដោយនិរន្តរភាព។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅ៖

- ការពារ អភិរក្សសត្វផ្សោតទន្លេមេគង្គ ដែលជិតផុតពូជ ដោយកាត់បន្ថយអត្រាស្លាប់ឲ្យនៅកម្រិតអប្បបរមា និងបង្កលក្ខណៈអំណោយផលដល់ការបន្តពូជពង្សរបស់ថនិកសត្វនេះ

- ការពារនិងថែរក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិនិងគុណភាពទឹកឲ្យមានប្រក្រតីភាពសម្រាប់ធានាការរីកលូតលាស់នៃជីវសាស្ត្រចម្រុះដែលទ្រទ្រង់ការរស់នៅរបស់សត្វផ្សោត
- គាំទ្រការអភិវឌ្ឍអេកូទេសចរណ៍សត្វផ្សោតទន្លេមេគង្គរបស់សហគមន៍មូលដ្ឋាន ដែលមិនបង្កផលប៉ះពាល់ ជាអវិជ្ជមានដល់និរន្តរភាពសត្វផ្សោត ដើម្បីការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជនបទនិងការកាត់បន្ថយភាពក្រីក្រ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៣.-**

តំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

## ជំពូកទី៣
## ការកំណត់តំបន់

**មាត្រា ៤.-**

តំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គលាតសន្ធឹងតាមដងទន្លេមេគង្គភាគខាងជើង ក្នុងកំណាត់ខាងលើប្រវែង១៨០គីឡូម៉ែត្រ ចាប់ពីខ្សែបន្ទាត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចំណុចល្បាក់ខោនទឹកធ្លាក់ព្រះនិមិត្ត-អន្លង់ឈើទាល-អន្លង់មរកត ក្នុងខេត្តស្ទឹងត្រែង មកទល់នឹងក្បាលកោះទ្រង់ក្នុងក្រុងក្រចេះ ខេត្តក្រចេះ មានទំហំ៧៧៦,៣០គីឡូម៉ែត្រការ៉េ ដោយមិនគិតបញ្ចូលតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិពិសេសជាទីជម្រកសត្វស្លាបទឹក ខេត្តស្ទឹងត្រែងទំហំ១៤៦គីឡូម៉ែត្រការ៉េ ដែលបានចុះក្នុងបញ្ជីនៃអនុសញ្ញារ៉ាំសា ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

ទំហំនិងព្រំប្រទល់តំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ អាចធ្វើការកែប្រែតាមការចាំបាច់ ដោយផ្អែកលើមូលដ្ឋានសិក្សាសេដ្ឋកិច្ចវិទ្យាសាស្ត្រ។ ការកែប្រែនេះត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៤
## ការចាត់ថ្នាក់និងការគ្រប់គ្រង

**មាត្រា ៦.-**

តំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គដែលលាតសន្ធឹងតាមដងទន្លេមេគង្គភាគខាងលើប្រវែង ៩៥គីឡូម៉ែត្រ ក្នុងខេត្តស្ទឹងត្រែងនិងប្រវែង៨៥គីឡូម៉ែត្រ ក្នុងខេត្តក្រចេះ ត្រូវបានបែងចែកជាតំបន់ស្នូលនិង

តំបន់ទ្រនាប់ ដោយផ្អែកទៅតាមវត្តមាន ទម្លាប់រស់នៅ និងការផ្លាស់ប្តូរទីកន្លែងរបស់សត្វផ្សោតតាមរដូវកាលនីមួយៗ៖

ក- **នៅរដូវប្រាំង** ចាប់ពីដើមខែវិច្ឆិកា ដល់ចុងខែឧសភាឆ្នាំបន្ទាប់ តំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គត្រូវបានបែងចែកជាតំបន់ស្នូលចំនួន៤កន្លែងនិងតំបន់ទ្រនាប់ចំនួន៤កន្លែង៖

**១- តំបន់ស្នូល**

តំបន់ស្នូលគឺជាកន្លែងបន្តពូជពង្សដ៏ពិសិដ្ឋជាពិសេសរបស់សត្វផ្សោតទន្លេមេគង្គ ហើយក៏ជាតំបន់ទឹកជ្រៅសម្បូរទៅដោយផ្ទាំងថ្មរកេតរកូត ព្រៃលិចទឹក តំបន់ដុះសារាយខ្មៅ ឆ្នេរខ្សាច់ និងអន្លង់ជ្រៅៗ ដែលជាកន្លែងបន្តពូជពង្សធម្មជាតិដ៏ពិសិដ្ឋរបស់ប្រភេទត្រីសម្បត្រីទន្លេនិងប្រភេទត្រីប្រចាំតំបន់ៗ

- **តំបន់ស្នូលទី១** ស្ថិតនៅក្នុងឃុំព្រះរំកិលនិងឃុំអូរស្វាយ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ ជាកំណាត់ទន្លេដែលព្រំប្រទល់ខាងជើងកំណត់ដោយខ្សែបន្ទាត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចំណុចអន្លង់ឈើទាល-អន្លង់មរកកនិងព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់បណ្តាចំណុច A4 ទៅ A5 ដែលមាននិយាមកា៖

  A4 ( ៦០៤៧៥១-១៥៣៥៩៥៣)    A5 ( ៦០៨៩៥៩-១៥៣៦២៨៨ )។

- **តំបន់ស្នូលទី២** ស្ថិតនៅក្នុងស្រុកសៀមបូក ខេត្តស្ទឹងត្រែងនិងស្រុកសំបូរ ខេត្តក្រចេះ មានផ្ទៃទឹកទំហំ១២២,២៧គីឡូម៉ែត្រការ៉េ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៣នៃអនុក្រឹត្យនេះ ជាកំណាត់ទន្លេដែលមានព្រំប្រទល់ខាងជើងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីក្បាលកោះស្រឡាយ ទៅចំណុច B និង B1 ត្រង់កន្លែងទឹកជ្រោះកាំងមេម៉ាយ មាននិយាមកា៖

  B ( ៥៩៩៧១៥-១៤៨៩៣២៣ )    B1 ( ៦០១៩៦១-១៤៨៩៤៩០ )

  និងព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច B2 ទៅ B3 ដែលមាននិយាមកា៖

  B2 ( ៦១៤៥០០-១៤៤៨៤៥៩ )    B3 ( ៦០៩៦៦៨-១៤៥២២៦៥ )។

- **តំបន់ស្នូលទី៣** ស្ថិតនៅក្នុងឃុំកំពង់ចាម ឃុំសំបូរ និងឃុំខ្សែរ ស្រុកសំបូរ ខេត្តក្រចេះ មានផ្ទៃទឹកទំហំ៦០,៩០គីឡូម៉ែត្រការ៉េ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៤នៃអនុក្រឹត្យនេះ ជាកំណាត់ខ្នែងទន្លេធំជាងគេ ដែលព្រំប្រទល់ខាងជើងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច C ទៅ C1 ត្រង់កន្លែង កាំងកោះព្រាង មាននិយាមកា៖

  C ( ៦០៧២៣៦-១៤៣៣៥៣៤ )    C1 ( ៦០៩២៥៨-១៤៣៣៦០២ )

  និងព្រំប្រទល់ខាងកើតកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច C2 ទៅ C3 មាននិយាមកា៖

  C2 ( ៦០៣៩៩០-១៤១៥៩៦៩ )    C3 ( ៦០៥៧៣៣-១៤១៣៦៧៦ )

  ហើយនិងព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច C4 ទៅ C5 មាននិយាមកា៖

  C4 ( ៦០៩៤៨០-១៤០៦៥៣០ )    C5 ( ៦០៧០៥១-១៤០៣៧៧៨ )។

- តំបន់ស្នូលទី៤ ស្ថិតនៅក្នុងឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វនិងឃុំសំបុក ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ មានផ្ទៃទឹកទំហំ២១,៦៥គីឡូម៉ែត្រការ៉េ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៥នៃអនុក្រឹត្យនេះ ជាកំណាត់ទន្លេដែលមានព្រំប្រទល់ខាងជើងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច D ទៅ D1 មាននិយាមកា ៖

  D (៦០៧៣១៨-១៣៩៥៥០២)  D1 (៦១១៣៧៨-១៣៩៥៥៤៧)

  និងព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច D2 ទៅ D3 ចំក្បាលកោះទ្រង់ មាននិយាមកា៖

  D2 (៦០៩៥៣៨-១៣៨៤២២៥)  D3 (៦០៧២៤៧-១៣៨៤២៥០)។

២- តំបន់ទ្រនាប់

តំបន់ទ្រនាប់ គឺជាជម្រករដូវប្រាំងដ៏ពិសិដ្ឋរបស់ពពួកមេពូជត្រីសម្បុកត្រីទន្លេនិងប្រភេទត្រីប្រចាំតំបន់ ដែលទម្លាប់មកសំងំលាក់ខ្លួនដើម្បីរីវឌ្ឍក្រពេញបន្តពូជ។ ជាទូទៅ តំបន់នេះសម្បូរទៅដោយផ្ទាំងថ្មរកេតរកូត ព្រៃលិចទឹក កន្លែងដុះសារាយខ្មៅជាចំណីបន្ថែមរបស់ត្រីមេពូជ អន្លង់ជ្រៅៗ និងឆ្នេរខ្សាច់។

- តំបន់ទ្រនាប់ទី១ ស្ថិតនៅក្នុងភូមិសាស្ត្រឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង មានផ្ទៃទឹកលាតសន្ធឹងរវាងដីគោកនិងខ្សែបន្ទាត់ព្រំដែនទឹកនៃព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចាប់ពីចំណុចល្បាក់ខោនទឹកធ្លាក់ព្រះនិមិត្ត ត្រង់ព្រំប្រទល់ខេត្តព្រះវិហារនិងខេត្តស្ទឹងត្រែង មកទល់ចំណុចកែងភូមិអន្លង់ស្វាយ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

- តំបន់ទ្រនាប់ទី២ ស្ថិតនៅក្នុងភូមិសាស្ត្រឃុំព្រះរំកិល ឃុំអូរស្វាយ ឃុំថាឡាបរិវ៉ាត់ ឃុំអូរ៉ី និងឃុំកាំងចាម ស្រុកថាឡាបរិវ៉ាត់និងសង្កាត់សាមគ្គី សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង មានផ្ទៃទឹកទំហំ១៥៣,៨៣គីឡូម៉ែត្រការ៉េ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៣នៃអនុក្រឹត្យនេះ ជាកំណាត់ទន្លេ ដែលព្រំប្រទល់ខាងជើងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច A4 ទៅ A5 និងព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ពីចំណុច B ទៅ B1 ដោយមិនគិតបញ្ចូលតំបន់ដីសើមជាជម្រកសត្វស្លាបទឹកខេត្តស្ទឹងត្រែងទំហំ១៤៦គីឡូម៉ែត្រការ៉េ។

- តំបន់ទ្រនាប់ទី៣ ស្ថិតនៅក្នុងឃុំអូរគ្រៀង ឃុំកោះខ្ញែ ឃុំបឹងចារ និងឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ មានផ្ទៃទឹកទំហំ២២៦,៨៤គីឡូម៉ែត្រការ៉េ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៤នៃអនុក្រឹត្យនេះ ជាកំណាត់ខ្នែងទន្លេតូចៗខាងកើត ដែលមានព្រំប្រទល់ខាងជើងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច B2 ទៅ B3 ព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច C ទៅ C1 និងព្រំប្រទល់ខាងត្បូងឆៀងខាងកើតកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច C2 ទៅ C3។

- តំបន់ទ្រនាប់ទី៤ គ្របដណ្តប់លើមួយផ្នែកនៃតំបន់កោះមួយពាន់ ស្ថិតនៅក្នុងឃុំសំបូរ ឃុំសណ្តាន់ ឃុំវឌ្ឍនៈ ស្រុកសំបូរនិងឃុំសំបុក ស្រុកចិត្របុរី ក្នុងខេត្តក្រចេះ មានផ្ទៃទឹកទំហំ[illegible]គីឡូម៉ែត្រការ៉េ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៥នៃអនុក្រឹត្យនេះ ជាកំណាត់ទន្លេដែលមានព្រំប្រទល់ខាង[illegible]

ជើងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច C4 ទៅ C5 និងព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច D ទៅ D1។

ខ- **នៅរដូវវស្សា ចាប់ពីដើមខែមិថុនា ដល់ចុងខែតុលា** ផ្ទៃទឹកទាំងអស់នៃតំបន់ការពារសត្វផ្សោតទន្លេមេគង្គទំហំ៣៨៩,៥០គីឡូម៉ែត្រការ៉េ ត្រូវកំណត់ជាតំបន់ស្នូលរដូវវស្សា ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៦នៃអនុក្រឹតនេះ ក្នុងនោះតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិពិសេសជាទីជម្រកសត្វស្លាបទឹក ខេត្តស្ទឹងត្រែង ទំហំ១៤៦គីឡូម៉ែត្រការ៉េ ត្រូវស្ថិតនៅ ក្រោមការគ្រប់គ្រងដោយឡែករបស់ក្រសួងបរិស្ថាន។

ផ្ទៃដីកោះទាំងអស់នៅក្នុងតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ ទាំងនៅក្នុងតំបន់ស្នូលរដូវប្រាំង ទាំងនៅក្នុងតំបន់ស្នូលរដូវវស្សាមានទំហំ៣៨៦,៨០គីឡូម៉ែត្រការ៉េ ត្រូវកំណត់ជាតំបន់ទ្រនាប់។

## មាត្រា ៧.-

ត្រូវចាត់វិធានការជាអាទិ៍តាមរយៈការអប់រំបណ្តុះបណ្តាលក្នុងគោលបំណងហាមឃាត់ដូចខាងក្រោម៖

- ការធ្វើនេសាទដោយឧបករណ៍មងគ្រប់ប្រភេទក្នុងតំបន់ស្នូលរដូវប្រាំងនិងរដូវវស្សា
- ការតាំងលំនៅជាផ្ទះទឹក ឬផ្ទះលើទូកនៅក្នុងតំបន់ស្នូលរដូវប្រាំង
- ការធ្វើវារីវប្បកម្មបែបឬស៊ីងក្នុងតំបន់ស្នូលរដូវប្រាំង
- ការធ្វើនាវាចរណ៍ដោយប្រើជលយានយន្តដែលមានល្បឿនលើសពី៣០គីឡូម៉ែត្រឬ២០ម៉ៃក្នុងមួយម៉ោង នៅក្នុងតំបន់ស្នូលរដូវប្រាំង
- ការប្រើប្រាស់ស្រឡាងដែលអាចចម្លងរថយន្តលើសពីបួនគ្រឿងឡើងទៅក្នុងតំបន់ស្នូលរដូវប្រាំង
- ការកាប់ឆ្ការព្រៃឬការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្តាកោះក្នុងតំបន់ការពារសត្វផ្សោតជាទ្រង់ទ្រាយធំដើម្បីបម្រើផលប្រយោជន៍ឯកជន។

អាចអនុញ្ញាត៖

- ការធ្វើនេសាទដោយប្រើឧបករណ៍មងក្រឡាតូចជាង៤សង់ទីម៉ែត្រឬ៤ហ៊ុន ដែលមានម្ចាស់ឬអ្នកនេសាទនៅឃ្លាំមើល នៅក្នុងតំបន់ទ្រនាប់រដូវប្រាំង
- ការសិក្សាស្រាវជ្រាវសេដ្ឋកិច្ចវិទ្យាសាស្ត្រ ការអភិវឌ្ឍអេកូទេសចរណ៍ ការអភិវឌ្ឍកសិកម្ម និងការដឹកជញ្ជូនឆ្លងកាត់ របស់ប្រជាពលរដ្ឋមូលដ្ឋាននៅក្នុងតំបន់ស្នូលនិងតំបន់ទ្រនាប់ ទាំងអស់
- ការនេសាទដោយឧបករណ៍នេសាទគ្រួសារមានដូចជា សំណាញ់ សន្ទូចផ្លែមួយ ចាន់ លប ទ្រូ ឈ្នាងត្រាំ សៃយ៉ឺនឬស៊ី និងថ្នងដែលគ្មានឧបករណ៍រួមផ្សំ នៅក្នុងតំបន់ស្នូលនិងតំបន់ទ្រនាប់។

## មាត្រា ៨.-

រដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ត្រូវសកម្មចូលរួមសហការ ដោយជួយផ្តល់មន្ត្រីក្រោមឱវាទនិងជួយលើកទឹកចិត្តពលរដ្ឋក្នុងមូលដ្ឋានឲ្យស្ម័គ្រចិត្តចូលរួមក្នុងក្រុមឆ្មាំទន្លេ ដើម្បីគ្រប់គ្រងតំបន់ការពារសត្វផ្សោតទន្លេមេគង្គជាប្រចាំប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមសំណើរបស់ស្ថាប័នមានសមត្ថកិច្ច។

អាជ្ញាធរមានសមត្ថកិច្ចត្រូវរៀបចំបោះបង្គោលសញ្ញាសម្គាល់ព្រំប្រទល់តំបន់ស្នូលនិងតំបន់ទ្រនាប់ ទាំងនៅលើដីគោក ទាំងនៅក្នុងទឹកនិងផែនទីដែលបញ្ជាក់ពីបទបញ្ញាដែលតម្រូវឲ្យអ្នកពាក់ព័ន្ធគោរពអនុវត្តតាម។

## ជំពូកទី៥
## ទោសប្បញ្ញត្តិ

**មាត្រា ៩.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

អនុក្រឹត្យនេះនិងផែនទីឧបសម្ព័ន្ធមិនពាក់ព័ន្ធនឹងបញ្ហាព្រំដែនរវាងប្រទេសនិងប្រទេសទេ។

**មាត្រា ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ប្រធានគណៈកម្មការអភិរក្សនិងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តក្រចេះនិង អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ [illegible] ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ២០១២**

**ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វស្លាបក្នុងទន្លេមេគង្គ ( ផ្ទៃដី ៧៧៦,៣ គ.ម² ) ខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ**







Coordinate System
Projection: UTM
Zone: 48 N
Spheroid: Everest
Datum : Indian 1960
Units : Kilometers
រៀបចំដោយរដ្ឋបាលជលផល

0 10 20 40
Kilometers

**និមិត្តសញ្ញាសម្គាល់**

- ចំណុចសម្គាល់និយាមកា
- តំបន់គ្រប់គ្រង និងការពារសត្វស្លាបក្នុងទន្លេមេគង្គ (ផ្ទៃដីសរុប= ៧៧៦,៣គម²)
- ផ្ទៃទឹក (៣៨៩,៤ គម²)
- ផ្ទៃដីគោក (៣៨៦,៩ គម²)

ព្រំប្រទល់រដ្ឋបាល

- ទីរួមឃុំ
- ទីរួមស្រុក
- ទីរួមខេត្ត
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០១២

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**អ៊ឹម ឈុនលឹម**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ចាន់.សារុន

**ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៩៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១២**

**ស្ដីពីការរៀបចំតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ (តំបន់ស្នូលទី១ ទំហំ ១៥,២៦ គ.ម² និងតំបន់ទ្រនាប់ទី១ ទំហំ ១,៩៥ គ.ម²) ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង**




## និមិត្តសញ្ញាសម្គាល់

- ចំណុចសម្គាល់និយាមកា
- តំបន់ស្នូលទី១
- តំបន់ទ្រនាប់ទី១
- ផ្ទៃទឹក
- ផ្ទៃដីគោក

**ព្រំប្រទល់រដ្ឋបាល**

- ទីរួមភូមិ
- ទីរួមឃុំ
- ទីរួមស្រុក
- ទីរួមខេត្ត
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត

Coordinate System
Projection: UTM
Zone: 48 N
Spheroid: Everest
Datum : Indian 1960
Units : Kilometers
រៀបចំដោយរដ្ឋបាលជលផល

**តារាងបង្ហាញផ្ទៃដីតំបន់ស្នូលទី១ និងតំបន់ទ្រនាប់ទី១ (គ.ម²)**

| | ផ្ទៃដីគោក | ផ្ទៃទឹក | ផ្ទៃដីសរុប |
|---|---|---|---|
| តំបន់ទ្រនាប់ទី១ | ០ | ១,៩៥ | ១,៩៥ |
| តំបន់ស្នូលទី១ | ៨,២៨ | ៦,៩៨ | ១៥,២៦ |

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០១២

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អ៊ឹម ឈុនលឹម | ចាន់ សារុន

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១២**

**ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការអភិរក្សធនធានជលផលទន្លេមេគង្គ (តំបន់ស្នូលទី ៣ ទំហំ ៦៤,៧៤ គ.ម² និងតំបន់ទ្រនាប់ទី ៣ ទំហំ ២២៦,៨៤ គ.ម²) ស្រុកសំបូរ ខេត្តក្រចេះ**




និមិត្តសញ្ញាសម្គាល់

- ចំណុចសម្គាល់និយាមការ
- តំបន់ស្នូលទឹក
- តំបន់ទ្រនាប់ទឹក
- ផ្ទៃទឹក
- ផ្ទៃគោក

ព្រំប្រទល់រដ្ឋបាល

- ទីរួមភូមិ
- ទីរួមឃុំ
- ទីរួមស្រុក
- ទីរួមខេត្ត
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត

Coordinate System
Projection: UTM
Zone: 48 N
Spheroid: Everest
Datum : Indian 1960
Units : Kilometers
រៀបចំដោយរដ្ឋបាលជលផល

**តារាងបង្ហាញផ្ទៃដីតំបន់ស្នូលទឹក និងតំបន់ទ្រនាប់ទឹក (គ.ម²)**

| | ផ្ទៃគោក | ផ្ទៃទឹក | ផ្ទៃដីសរុប |
|---|---|---|---|
| តំបន់ទ្រនាប់ទឹក | ១៦៥,០៩ | ៦១,៧៥ | ២២៦,៨៤ |
| តំបន់ស្នូលទឹក | ៣,៩២ | ៦០,៨២ | ៦៤,៧៤ |

បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១២

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥៥អនក្រ.បក ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១២

### ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ (តំបន់ស្ទូងរដូវវស្សា មិថុនា - វិច្ឆិកា ទំហំ ៣៥៩,៥ គ.ម២) ខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ







និមិត្តសញ្ញាសម្គាល់

Coordinate System
Projection: UTM
Zone: 48 N
Spheroid: Everest
Datum : Indian 1960
Units : Kilometers

បានឃើញនិងឯកភាព

ធ្វើនៅភ្នំពេញ ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០១២

អ៊ឹម ឈុនលឹម

ឆ័ន្ទ សារុន

**ឧបសម្ព័ន្ធ៣នៃអនុក្រឹត្យលេខ [illegible] ចុះថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ២០១២**

**ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការអភិរក្សធនធានជលផលនៃទន្លេមេគង្គ (តំបន់ស្នូលទី២ ទំហំ ២៦០,៥៦ គ.ម² និងតំបន់ទ្រនាប់ទី២ ទំហំ ១៥៣,៨៣ គ.ម²) ខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ**




**និមិត្តសញ្ញាសម្គាល់**

- ចំណុចសម្គាល់និយាមកា
- តំបន់ស្នូលទី២
- តំបន់ទ្រនាប់ទី២
- ផ្ទៃទឹក
- ផ្ទៃដីគោក

**ព្រំប្រទល់រដ្ឋបាល**

- ទីរួមឃុំ
- ទីរួមស្រុក
- ទីរួមខេត្ត
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត

Coordinate System
Projection: UTM
Zone: 48 N
Spheroid: Everest
Datum : Indian 1960
Units : Kilometers
រៀបចំដោយរដ្ឋបាលជលផល

**តារាងបង្ហាញផ្ទៃដីតំបន់ស្នូលទី២ និងតំបន់ទ្រនាប់ទី២ (គ.ម²)**

| | ផ្ទៃដីគោក | ផ្ទៃទឹក | ផ្ទៃដីសរុប |
|---|---|---|---|
| តំបន់ទ្រនាប់ទី២ | ៧៣,១៦៨ | ៨០,៦៦ | ១៥៣,៨ |
| តំបន់ស្នូលទី២ | ១៣៥,១១ | ១២៥,៤ | ២៦០,៥៦ |

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ២០១២

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អ៊ឹម ឈុនលឹម

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥៥អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១២

ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ (តំបន់ស្នូលទី ៤ ទំហំ ២៣,០២ គ.ម² និងតំបន់ទ្រនាប់ទី ៤ ទំហំ ៣០,១៤ គ.ម²) ខេត្តក្រចេះ




**និមិត្តសញ្ញាសម្គាល់**

- ចំណុចសម្គាល់និយាមកា
- តំបន់ស្នូលទី៤
- តំបន់ទ្រនាប់ទី៤
- ផ្ទៃទឹក
- ផ្ទៃដីគោក

**ព្រំប្រទល់រដ្ឋបាល**

- ទីភូមិ
- ទីឃុំ
- ទីស្រុក
- ទីខេត្ត
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត

Coordinate System
Projection: UTM
Zone: 48 N
Spheroid: Everest
Datum : Indian 1960
Units : Kilometers
រៀបចំដោយរដ្ឋបាលជលផល

**តារាងបង្ហាញផ្ទៃដីតំបន់ស្នូលទី៤ និងតំបន់ទ្រនាប់ទី៤ (គ.ម²)**

| | ផ្ទៃដីគោក | ផ្ទៃទឹក | ផ្ទៃដីសរុប |
|---|---|---|---|
| តំបន់ទ្រនាប់ទី៤ | ៦,០៨ | ២៤,០៦ | ៣០,១៤ |
| តំបន់ស្នូលទី៤ | ១,៥៨ | ២១,៤៤ | ២៣,០២ |

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០១២

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ច័ន្ទ សារុន